# I . ទីស្ដីការគណៈរដ្ឋមន្ត្រី

## ១-អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៥

### អនុក្រឹត្យលេខ ៥៦ អនក្រ.បក

ស្ដីពីការបង្កើតក្រុមប្រឹក្សាស្ដារ

អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ

* * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាពនៃរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណូមពរការងារចាំបាច់

### សំរេច

មាត្រា ១ : បង្កើតក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ដែលមានសមាសភាពដូតទៅ ៖

១-សម្ដេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១

| | | | |
|---|---|---|---|
| ២–សម្តេចនាយករដ្ឋមន្ត្រីទី ២ | | | សហប្រធាន |
| ៣–ឯកឧត្តម | **តាវ សេងហួរ** | រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ | អនុប្រធាន |
| ៤–ឯកឧត្តម | **គាត ឈន់** | ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនិតិសម្បទា និង អភិវឌ្ឍន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥–ឯកឧត្តម | **ថោ ប៉េងលាត** | អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៦–ឯកឧត្តម | **ចម ប្រសិទ្ធ** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧–ឯកឧត្តម | **ជា ចាន់តូ** | រដ្ឋមន្ត្រីក្រសួងផែនការ | សមាជិក |
| ៨–ឯកឧត្តម | **ហុង ស៊ុនហួត** | រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៩–ឯកឧត្តម | **នូវ កាណុន** | រដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១០–ឯកឧត្តម | **ត្រាំ អ៊ីវទឹក** | រដ្ឋលេខាធិការក្រសួងសាធារណការ និង ដឹកជញ្ជូន | សមាជិក |
| ១១–លោក | **ជុំ ប៊ុនរ៉ុង** | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ | សមាជិក |
| ១២–លោក | **លឹម គានហោ** | ប្រធាននាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រ | សមាជិក |
| ១៣–លោក | **សារ៉ាក់ ខាន់** | អគ្គនាយក នាយកខុទ្ទកាល័យ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អគ្គលេខាធិការ |

**មាត្រា ២ :** ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានតួនាទីជាគណៈបញ្ជាការឯកភាពមួយ ដោយសហការគ្នាយ៉ាងជិតស្និទ្ធជាមួយបណ្តាក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ជាពិសេសជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីអនុវត្តអោយស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នា និង មានប្រសិទ្ធភាព ព្រមទាំងមានសិទ្ធិសំរេចអំពីមធ្យោបាយ សម្ភារៈ ទុន និង ការងារផ្សេង ១ ទៀត ដែលជួយអោយសំរេចរាល់ភារកិច្ចដែលមានចែងក្នុងមាត្រា ៣ ។

**មាត្រា ៣ :** ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានភារកិច្ចដូចខាងក្រោម ៖

- ទទួលបន្ទុកចាត់ចែងអនុវត្តនូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និង កម្មវិធីជាតិនីតិសម្បទា និង អភិវឌ្ឍន៍កម្ពុជា លើកិច្ចការស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ សំដៅប្រែក្លាយវិស័យកសិកម្មដែលមានទំលាប់ធ្វើដើម្បីផ្គត់ផ្គង់ខ្លួនឯង អោយទៅជាការផលិតដើម្បីនាំចេញ ព្រមទាំងបន្ថយជាជំហាន ។ នូវគម្លាតឆ្ងាយរវាងជនបទ និង ទីក្រុង ។
- កំណត់កត្តាគន្លឹះទាំងឡាយដែលបំរើអោយការស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ។
- កំណត់អាទិភាព នៃតម្រូវការក្នុងការស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ទៅតាមកម្មវិធី និង តាមសភាពការណ៍ជាក់ស្តែង ។
- ចលនា និង សំរបសំរួលរវាងគ្រប់សមាសភាពសេដ្ឋកិច្ច ជាពិសេសក្រុមហ៊ុនឯកជនជាមួយក្រសួង ស្ថាប័ន ខេត្ត-ក្រុង ដើម្បីបង្កនូវភាពងាយស្រួល និង ភាពសហការគ្នាល្អក្នុងការស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ។
- ពិនិត្យ និងសំរេចលើរាល់សេចក្តីស្នើសុំស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ព្រមទាំងផ្តល់យោបល់ណែនាំដល់ក្រសួង ស្ថាប័ន និង ខេត្ត-ក្រុង ។ រាយការណ៍ និង សុំយោបល់រាជរដ្ឋាភិបាលលើបញ្ហាសំខាន់ ។ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៤ :** ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានភារកិច្ចបង្កើតលេខាធិការដ្ឋានមួយ ដើម្បីជួយការងារ ។

**មាត្រា ៥ :** សមាជិកក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**មាត្រា ៦ :** ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានសិទ្ធិប្រើប្រាស់ត្រារបស់គណៈរដ្ឋមន្ត្រី ។

**មាត្រា ៧ :** ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន សំរាប់ដំណើរការជាក់ស្តែង ។

**មាត្រា ៨ :** អនុក្រឹត្យលេខ ៧១ អនក្រ. ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៩ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គទេសាភិបាលនៃធនាគារជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និង សម្តេច ឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងមាត្រា ១ ព្រមទាំងបណ្តាក្រសួង - ស្ថាប័ន និង ខេត្ត-ក្រុង ដែលមានការពាក់ព័ន្ធ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៨១ អនក្រ.គត**

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ. ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និង ប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២